# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការក្រសួងយុត្តិធម៌
លេខ ១១៤០ រប-៩៦

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**ជម្រាបចក**

លោកប្រធានតុលាការខេត្ត ក្រុង

លោកព្រះរាជអាជ្ញាអមតុលាការខេត្ត ក្រុង

**សូមជ្រាប។**

**កម្មវត្ថុ:** ស្តីពីការអនុវត្ត ច្បាប់ ។

ខ្ញុំបាទទទួលព័ត៌មានថា តុលាការអយ្យការខេត្ត-ក្រុង ខ្លះរង់ចាំអនុក្រឹត្យណែនាំសិនមុននិងអនុវត្តច្បាប់ដូចជាថ្មីៗនេះច្បាប់ស្តីពីការបង្ក្រាបអំពើពង្រត់ និងលក់ដូរមនុស្ស នឹងអំពើធ្វើអាជីវកម្មលើមនុស្ស ។ ខ្ញុំសូមជម្រាបអស់លោកថា ច្បាប់ដែលចូលជាធរមានហើយ គឺនៅរាជធានីភ្នំពេញ ១០ថ្ងៃ ក្រោយ ថ្ងៃប្រកាសអោយប្រើនិងនៅខេត្ត-ក្រុង ទូទាំងប្រទេស ២០ថ្ងៃក្រោយ ថ្ងៃប្រកាសអោយប្រើ តុលាការនិងអយ្យការចាប់អនុវត្តបានហើយ ឥតត្រូវរង់ចាំអនុក្រឹត្យ ឬការណែនាំអ្វីពីក្រសួងយុត្តិធម៌ឡើយ ។

បើច្បាប់ដែលមានចែងថាជាការប្រញាប់ ច្បាប់នេះចូលជាធរមានភ្លាម នៅទូទាំងប្រទេស បន្ទាប់ពីថ្ងៃប្រកាសអោយប្រើ ។

ច្បាប់ទាំងអស់ដែលរដ្ឋសភាបានអនុម័ត ក្រសួងបានផ្ញើមកជូនតុលាការ ១ច្បាប់ និងជូនមកអយ្យការ១ច្បាប់ សម្រាប់អនុវត្ត។មានចៅក្រមខ្លះបានប្រាប់លោកតំណាងពិសេសអគ្គលេខាធិការ អ.ស.ប ខាងសិទ្ធិមនុស្សថាមិនបានដឹងមានច្បាប់អ្វីខ្លះដែលរដ្ឋសភាបានអនុម័តនោះទេ ខ្ញុំសូមលោកប្រធានតុលាការ និងលោកព្រះរាជអាជ្ញាទុកអត្ថបទច្បាប់ទាំងនេះនៅបណ្ណាល័យ ដើម្បីទាំងអស់គ្នាក្នុងតុលាការ និងអយ្យការប្រើប្រាស់ ។ អស់លោកជាចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី ដែលចង់បានផ្ទាល់ខ្លួនអាចសរសេរមកសុំទិញពីទីស្តីគណៈរដ្ឋមន្ត្រី ដែលមានចងក្រងលក់ ១ ក្បាលតម្លៃ ២០,០០០ រៀល ឬមកសុំឱ្យក្រសួងជួយចងក្រងឱ្យដោយបង់ថ្លៃក្រដាស់ និងថ្លៃថតចម្លងប៉ុណ្ណោះ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី១៦ ខែតុលា ឆ្នាំ១៩៩៦

**រដ្ឋមន្ត្រី**

**ចែម ស្ងួន**